ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤៥៦២ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបំពេញបន្ថែមកម្រងសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទៈ (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី
- បានឃើញអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសអន្តរក្រសួងលេខ៣៥៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .‒**

កម្រងសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលកំណត់ដោយប្រកាសអន្តរក្រសួងលេខ៣៥៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ត្រូវបានបំពេញបន្ថែមប្រភេទសេវាមួយចំនួនដូចខាងក្រោម ÷

| ល.រ | បរិយាយប្រភេទសេវា<br>ដែលបំពេញបន្ថែម | តម្លៃឯកតា<br>នៃសេវា<br>(រៀល) | រយៈពេលអតិបរមា<br>នៃការផ្តល់សេវា<br>(ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១- | ការផ្តល់វិញ្ញាបនបត្រវាស់វែងលើកដំបូង សម្រាប់អ្នកវាស់វែង (យោងប្រការ៩ នៃប្រកាសលេខ១៧៥ ដនស/ប្រក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) | | | |
| - | កម្រិត ក | ១.៦០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| - | កម្រិត ខ | ១.២០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| - | កម្រិត គ | ៨០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| ២- | ការបន្តសុពលភាពវិញ្ញាបនបត្រវាស់វែង | | | |
| - | កម្រិត ក | ១.៤០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| - | កម្រិត ខ | ១.០០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| - | កម្រិត គ | ៦០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| ៣- | ការដំឡើងកម្រិតវិញ្ញាបនបត្រវាស់វែង សម្រាប់អ្នកវាស់វែង | | | |
| - | កម្រិត ខ ទៅកម្រិត ក | ១.៦០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| - | កម្រិត គ ទៅកម្រិត ក | ១.៦០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| - | កម្រិត គ ទៅកម្រិត ខ | ១.២០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| ៤- | ការបន្ថយកម្រិតវិញ្ញាបនបត្រវាស់វែង សម្រាប់អ្នកវាស់វែង | | | |
| - | កម្រិត ក ទៅកម្រិត គ | ៨០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| - | កម្រិត ក ទៅកម្រិត ខ | ៨០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| - | កម្រិត ខ ទៅកម្រិត គ | ៨០០.០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| ៥- | ការចេញបណ្ណទុតិយតា តតិយតា វិញ្ញាបនបត្រវាស់វែង (ក្នុងមួយបណ្ណ) | ៤០០.០០០ | ១៥ថ្ងៃ | ដូចសុពលភាពដើម |
| ៦- | ការផ្តល់ទិន្នន័យវាស់វែងគោលរបស់ស្ថានីយវាស់វែងអចិន្ត្រៃយ៍ តាមរយៈផ្កាយរណប ក្នុងមួយគណនីអេឡិចត្រូនិក | ១.០០០.០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| ៧- | ការផ្តល់អាជ្ញាប័ណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ សម្រាប់ក្រុមហ៊ុន (យោងអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០) | | | |
| - | កម្រិត ១ | ៦.០០០.០០០ | ២០ថ្ងៃ | ៣ឆ្នាំ |
| - | កម្រិត ២ | ៤.០០០.០០០ | ២០ថ្ងៃ | ៣ឆ្នាំ |
| - | កម្រិត ៣ | ៣.០០០.០០០ | ២០ថ្ងៃ | ៣ឆ្នាំ |
| ៨- | ការបន្តសុពលភាពអាជ្ញាប័ណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ សម្រាប់ក្រុមហ៊ុន | | | |
| - | កម្រិត ១ | ៣.០០០.០០០ | ២០ថ្ងៃ | ៣ឆ្នាំ |

| | | | | |
|---|---|---|---|---|
| - | កម្រិត ២ | ២.០០០.០០០ | ២០ថ្ងៃ | ៣ឆ្នាំ |
| - | កម្រិត ៣ | ១.០០០.០០០ | ២០ថ្ងៃ | ៣ឆ្នាំ |
| ៩- | ការផ្តល់អាជ្ញាប័ណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ សម្រាប់អ្នកវិជ្ជាជីវៈ | ៨០០.០០០ | ២០ថ្ងៃ | ៣ឆ្នាំ |
| ១០- | ការបន្តសុពលភាពអាជ្ញាប័ណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ សម្រាប់អ្នកវិជ្ជាជីវៈ | ៦០០.០០០ | ២០ថ្ងៃ | ៣ឆ្នាំ |
| ១១- | ការបញ្ចប់សុពលភាពអាជ្ញាប័ណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ | ៤០០.០០០ | ២០ថ្ងៃ | |
| ១២- | ការចេញសន្លឹកអាជ្ញាប័ណ្ណថ្មី ចំពោះអាជ្ញាប័ណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ | ៤០០.០០០ | ២០ថ្ងៃ | ដូចសុពលភាពដើម |

**ប្រការ២ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ